00327264

D130/6

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 18 / 05 / 2009
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: CA.Ly

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស |
| **ដាក់ជូន:** | ការិយាល័យសហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទដាក់ឯកសារ:** | ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ២០០៩ |
| **ភាគីដាក់ឯកសារ:** | សហមេធាវីការពាររបស់ អៀង ធីរិទ្ធ |
| **ភាសា:** | ភាសាអង់គ្លេស (ឯកសារដើម) និង ភាសាខ្មែរ (អត្ថបទបកប្រែ) |
| **ប្រភេទឯកសារស្នើឡើងដោយភាគីដាក់ឯកសារ:** | សាធារណៈ |

19/05/2009

---

**ចម្លើយតបរបស់មេធាវីការពារលើ "ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់មេធាវីការពារ អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម"**

---

**ដាក់ឯកសារដោយ៖**
**សហមេធាវីរបស់ អៀង ធីរិទ្ធ**
**លោក ផាត់ ពៅស៊ាង**
**កញ្ញា** Diana ELLI, QC

**ចែកចាយជូន៖**
**សហចៅក្រមស៊ើបអង្កេត**
**លោក យូ ប៊ុនឡេង**
**លោក** Marcel LEMONDE

**សហព្រះរាជអាជ្ញា:**
**អ្នកស្រី ជា លាង**
**លោក** Robert PETIT

**ក្រុមមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / MAY / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ERN/KH: D130/6



**មាតិកា**


I. **សេចក្ដីផ្ដើម និង គោលបំណង** ..................................................២

II. **បញ្ហាបច្ចុប្បន្នទាក់ទងនឹងព័ត៌មានថ្មីៗ** ..................................................២

២.១ សេចក្ដីថ្លែងថ្មីៗរបស់ ឌុចនៅក្នុងសំណុំរឿងលេខ00១..................................................២

២.២ សេចក្ដីប្រកាសព័ត៌មានរបស់អង្គការលើកលែងទោសអន្តរជាតិ..................................................៣

២.៣ សេចក្ដីសន្និដ្ឋាន..................................................៤

III. **អំណះអំណាង**..................................................៥

៣.១ ការបកស្រាយច្បាប់មិនត្រឹមត្រូវ..................................................៥

៣.២ ចម្លើយតបរបស់ ក.ស.ព ខកខានមិនបានឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវលើមាត្រា ១៥ នៃ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (CAT) ..................................................៦

៣.៣ ពុំមានភាពបត់បែននៅក្នុងការច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម......៨

៣.៤ ប្រភេទនៃភស្តុតាង..................................................១២

IV. **សេចក្ដីសន្និដ្ឋាន**..................................................១៧

V. **សំណូមពរ**..................................................១៨

## I. សេចក្តីផ្តើម និង ការលប្យចត្តិ

1. មេធាវីការពាររបស់អ្នកស្រី អៀង ធីរិទ្ធ កាលពីថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ បានដាក់ "សំណើរបស់ខ្លួន សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម" ("សំណើសុំរបស់មេធាវីការពារ")[1]។

2. នៅពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩ ក.ស.ព បានដាក់ "ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់មេធាវីការពារ អៀង ធីរិទ្ធ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ ២០០៩" ("ចម្លើយតបរបស់ ក.ស.ព") ដែលបានជូនដំណឹងដល់គ្រប់ភាគីទាំងអស់នៅមួយសប្តាហ៍ក្រោយមក គឺនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០០៩[2]។ មេធាវីការពារសូមដាក់ចម្លើយតបរបស់ខ្លួនទៅនឹងការឆ្លើយរបស់ ក.ស.ព ("ចម្លើយតប") ដូចតទៅនេះ។

## II. បញ្ហាបន្ថែមពាក់ព័ន្ធនឹងព័ត៌មានថ្មីៗ

### ២.១ សេចក្តីថ្លែងថ្មីៗរបស់ ឌុច នៅក្នុងសំណុំរឿង០០១

3. ចាប់តាំងពីដាក់សំណើសុំច្រានចោលភស្តុតាងមក មានការវិវឌ្ឍន៍ថ្មីៗនៅក្នុងសំណុំរឿង ឌុច (សំណុំរឿង ០០១)។ នៅក្នុងកាលៈទេសៈបែបនេះ មេធាវីការពារយល់ឃើញថា ការវិវឌ្ឍន៍នេះ គឺជាប់ពាក់ព័ន្ធជាមួយអំណះអំណាងដែលបានលើកឡើង ហើយវានឹងជាជំនួយដល់ ក.ស.ច.ស ប្រសិនបើវាត្រូវបានគេបង្ហាញដល់ ក.ថ.ស.ច នៅដំណាក់កាលនេះ។

4. កាលពីថ្ងៃទី ៧ មេសា ឆ្នាំ ២០០៩ នៅក្នុងការឆ្លើយតបទៅនឹងសំនួររបស់លោកចៅក្រម Laverge ឌុច បានថ្លែងនៅក្នុងអង្គសវនាការដូចខាងក្រោម:

> [...] ខ្ញុំមិនដែលជឿថា ចម្លើយដែលខ្ញុំទទួលបានស្របនឹងការពិតទេ។ យ៉ាងច្រើនណាស់បាន ៤០ ភាគរយប៉ុណ្ណោះ ។ [...]

---

[1] សំណើរបស់មេធាវីការពារ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ១១ កុម្ភៈ ២០០៩, ឯកសារលេខ D130 ។

[2] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសំណើរបស់មេធាវីការពារ សុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ១១ កុម្ភៈ ២០០៩, ៣០ មេសា ២០០៩, ឯកសារលេខ D135/5 ។

> ដូច្នេះ ចម្លើយដែលខ្ញុំទទួលបានអំពីបែបណាក៏ដោយ យ៉ាងច្រើនបានពិតត្រឹម ៤០%។ [...] ប៉ុន្តែមនុស្សដែលគេឆ្លើយដាក់យ៉ាងច្រើនពិតត្រឹម ២០% ។ [...] ប៉ុន្តែ គ្មានស្ដីជាការថ្នឹមប្រៀបដើម្បីយល់ប៉ុន្មានភាគរយច្បាស់ទេ[3]។

5. នៅសវនាការនាថ្ងៃបន្ទាប់ បន្ទាប់ពីបានគិតត្រឡប់ក្រោយច្រើនថែមទៀត ឌុច កាត់បន្ថយភាគរយនៃការពិតដែលមាននៅក្នុងចម្លើយសារភាពមកត្រឹមតែ ២០% តែប៉ុណ្ណោះ។ គាត់បាននិយាយថា:

> ខ្ញុំនៅតែទទួលថា សេចក្ដីសារភាពដែលយើងខ្ញុំទទួលបានមិនស្របនឹងការពិតទាំងស្រុងទេ យ៉ាងច្រើនណាស់ ២០ ភាគរយ យ៉ាងច្រើនណាស់ ២០ ភាគរយហ្នឹង យ៉ាងច្រើនម្ភៃភាគរយនៃខ្លឹមសារដែលឆ្លុះបញ្ចាំងពីការពិតនោះ។ [...] អាម្ភៃភាគរយដែលខ្ញុំតែងតែនិយាយ ថាជាសេចក្ដីសារភាពវាមិនដែលពិត ពីព្រោះវាខុសពីស្ថានភាពពិត[4]។

6. សេចក្ដីថ្លែងរបស់ ឌុច នៅក្នុងអង្គសវនាការ គាំទ្រដល់គោលជំហរបស់មេធាវីការពារដែលថា សេចក្ដីសារភាព និង ភស្តុតាងដទៃទៀតដែលទទួលបានមកពីការធ្វើទារុណកម្ម គឺមិនអាចជឿទុកចិត្តបាន ហើយទោះបីជាតាមរបៀបណាក៏ដោយ ក៏ភស្តុតាងបែបនេះមិនអាចយកមកសំអាងនៅក្នុងតុលាការបានឡើយ លើកលែងតែយកមកបង្ហាញពីការប្រព្រឹត្តទារុណកម្មប៉ុណ្ណោះ។

**២.២ សេចក្ដីប្រកាសព័ត៌មានរបស់អង្គការលើកលែងទោសអន្តរជាតិ**

7. នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ គឺចាំថ្ងៃ ក.ស.ព ដាក់ចម្លើយតបរបស់ខ្លួន ព្រឹត្តិប័ត្រសារព័ត៌មានឌឹខែមបូឌាដេលី បានផ្សព្វផ្សាយអត្ថបទមួយទាក់ទងនិងខ្លឹមសារញត្តិរបស់មេធាវីការពារ[5] ដែលបានលើកឡើងនូវសំដីរបស់លោក Yuval Ginbar ទីប្រឹក្សាច្បាប់នៃអង្គការលើកលែងទោសអន្តរជាតិសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិច និង ជាអ្នកនិពន្ធសៀវភៅ "*ហេតុអ្វីបានជាមិនធ្វើទារុណកម្មលើភេរវករ? (Why Not Torture Terrorists?)* លោកបានថ្លែងថា:

---

[3] ប្រតិចារិក ចុះថ្ងៃទី ៧ មេសា ២០០៩ សំណុំរឿង ឯកសារលេខ E1/9.1, ទំព័រ 22 (បន្ទាត់ 4-6, 10-12 និង 16-17 ។

[4] ប្រតិចារិក ចុះថ្ងៃទី ៨ មេសា ២០០៩ សំណុំរឿង ឯកសារលេខ E1/10.1, ទំព័រ 105 (បន្ទាត់ 8-11, 10-12, ទំព័រ 106 បន្ទាត់ 20-21) (អត្ថបទអង់គ្លេស) ។

[5] Douglas Gillison, "អៀង ធីរិទ្ធ: ចម្លើយសារភាពនៅ ស២១ 'ជិតងាមដោយការធ្វើទារុណកម្ម" ព្រឹត្តិប័ត្រសារព័ត៌មានឌឹខែមបូឌាដេលី ចុះថ្ងៃទី ៣០ មេសា ២០០៩ ទំព័រ 1-2 ។

ការព្យាយាមធ្វើយុត្តិកម្មលើការប្រើប្រាស់ចម្លើយសារភាពដែលបានមកពីការធ្វើទារុណកម្ម ជាមធ្យោបាយតែមួយគត់ "ដើម្បីនាំមកនូវយុត្តិធម៌" គឺមិនដូចគ្នានឹងការព្យាយាមធ្វើយុត្តិកម្មលើការធ្វើទារុណកម្មលើខ្លួនឯង ជាមធ្យោបាយតែមួយគត់ដើម្បីជួយសង្គ្រោះជនស៊ីវិលពីការវាយប្រហារដោយអំពើភេរវកម្ម នោះឡើយ។

[...]

ភស្តុតាង [ដែលផលិតដោយការធ្វើទារុណកម្ម] មិនត្រូវបានពិចារណាដោយអង្គសវនាការជាផ្នែកមួយនៃដំណើរការនីតិវិធីព្រហ្មទណ្ឌស្របច្បាប់ឡើយ ។

8. សេចក្តីថ្លែងបែបនេះបានដៅបញ្ជាក់ពីជំហរបស់មេធាវីការពារក្តីកាន់តែខ្លាំងថែមទៀត ដូចដែលបានលើកឡើងនៅក្នុងសំណើ និង ចម្លើយតបនេះ។

## ២.៣ សេចក្តីសន្និដ្ឋាន

9. សេចក្តីថ្លែងរបស់ ឌុច ត្រូវបានធ្វើឡើងបន្ទាប់ពីមេធាវីការពារដាក់សំណើសុំ ក៏ដូចជាសេចក្តីថ្លែងដែលធ្វើឡើងដោយលោក Yuval Ginbar នៃអង្គការលើកលែងទោសអន្តរជាតិ (ដាក់ជា "ឯកសារបន្ថែម") ហើយអាស្រ័យហេតុនេះ មេធាវីការពារក្តីមិនលើកបញ្ហាទាំងនេះដាក់នៅក្នុងសំណើសុំរបស់ខ្លួនបានទេ។

10. ប៉ុន្តែ មេធាវីការពារបានលើកឡើងថា ភស្តុតាងនេះជួយដល់ការយល់ដឹងលើបញ្ហានេះ ហើយដែល ក.ស.ច.ស។ ត្រូវតែពិចារណា ។

11. សេចក្តីថ្លែងពាក់ព័ន្ធរបស់ ឌុច ត្រូវបានធ្វើឡើងមុន ក.ស.ព ដាក់ចម្លើយតបរបស់ខ្លួន ប៉ុន្តែ មេធាវីការពារកត់សំគាល់ថា ក.ស.ព មិនបានពិចារណាលើសេចក្តីថ្លែងរបស់គាត់ឡើយ។ លោក Yuval Ginbar បានធ្វើសេចក្តីថ្លែងរបស់គាត់នៅក្នុងព្រឹត្តិប័ត្រសារព័ត៌មានពីខែមុនដោយនៅថ្ងៃ ក.ស.ព ដាក់ចម្លើយតបរបស់ខ្លួន ហើយអាស្រ័យហេតុនេះ ក.ស.ព ពុំមានឱកាសឆ្លើយតបទៅលើចំនុចពិសេសនេះ។

12. ប្រសិនបើ ក.ស.ព មានបំណងឆ្លើយតបចំពោះ ឯកសារបន្ថែមនេះ មេធាវីការពារក្តីស្នើសុំឱ្យ ក.ស.ច.ស ចេញដីកាបង្គាប់ទៅ ក.ស.ព ឱ្យដាក់ចម្លើយតបនឹងមួយ ដើម្បីឱ្យសំណើនេះអាចត្រូវ

បានដោះស្រាយនៅក្នុងថេរៈវេលាសមស្របមួយ ជាពិសេស ទាក់ទងនឹងពេលវេលាជាច្រើនដែលបានកន្លងផុតទៅ ចាប់តាំងពីការដាក់សំណើរបស់មេធាវីការពារនៅថ្ងៃទី ១១ កុម្ភៈ ២00៨ មក។

## III. **អំណះអំណាង**

### ៣.១ ការបកស្រាយច្បាប់មិនត្រឹមត្រូវ

13. មេធាវីការពារសូមលើកឡើងថា ខ្លួនបានលើកឡើងយ៉ាងពេញលេញអំពីច្បាប់ដែលនៅជាធរមាននៅក្នុងសំណើរបស់ខ្លួន។ ប៉ុន្តែ នៅក្នុងទិដ្ឋភាពជាច្រើននៃចម្លើយតបរបស់ ក.ស.ព បានបកស្រាយច្បាប់ដោយមិនត្រឹមត្រូវ ដែលមេធាវីការពារសូមទាញចំណាប់អារម្មណ៍របស់ ក.ស.ច.ស លើចំនុចនេះ។

14. ជាបឋម ការបកស្រាយមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា កថាខណ្ឌ ៦ នៃចម្លើយតបរបស់ ក.ស.ព ចែងថា:

    មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ច្រានចោលសេចក្តីសារភាពដែលជា “ភស្តុតាងនៃពិរុទ្ធភាព” និងបានកត់សំគាល់ថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ “ជនជាប់ចោទ” ឧទាហរណ៍ ជនរងគ្រោះនៃការធ្វើទារុណកម្ម ។

15. ក.ស.ព ទាញយកផលប្រយោជន៍ដោយមិនត្រឹមត្រូវពីការបកស្រាយរបស់ខ្លួនលើបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញនេះ ដោយពុំបានផ្តល់ការពន្យល់ចំពោះការអានក្នុងន័យទូលំទូលាយបែបនេះ។ មាត្រា ៣៨ មិនអនុវត្តចំពោះតែជនជាប់ចោទដែលជាជនរងគ្រោះនៃអំពើទារុណកម្មប៉ុណ្ណោះទេ តែថែមទាំងអនុវត្តទៅលើជនជាប់ចោទគ្រប់រូបនៅក្នុងសវនាការរឿងក្តីព្រហ្មទណ្ឌផងដែរ។ មាត្រា ៣៨ មានន័យយ៉ាងច្បាស់ថា:

    ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

16. ក.ស.ព ធ្វើសេចក្តីសន្និដ្ឋានថា[6] [“ច្បាប់កម្ពុជាដែលសំអាងដោយមេធាវីការពារបានគាំទ្រដល់សញ្ញាណដែលថា ការហាមឃាត់ដល់ការប្រើប្រាស់ភស្តុតាងនេះ គឺសំដៅទៅលើការប្រើប្រាស់វាប្រឆាំងនឹងជនរងគ្រោះនៃអំពើទារុណកម្ម” ដែលត្រូវតែបដិសេធចោល។

---

[6] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៦។

17. ទីពីរ កថាខណ្ឌ ១៣ នៃចម្លើយតបរបស់ ក.ស.ព បានយោងមាត្រា ១៦ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម (CAT)។ មាត្រានេះបង្ហាញថា វាក្យស័ព្ទនៃអំពើទារុណកម្មនៅក្នុងបទប្បញ្ញត្តិ CAT អាចត្រូវបានគេយល់ថាជា "អំពើឃោរឃៅ អមនុស្សធម៌ ឬ ការបន្ថោកបន្ទាប ឬ ទណ្ឌកម្ម [...]" ប៉ុន្តែ មិនចែងនៅក្នុងមាត្រា ១៥ នៃអនុសញ្ញានេះទេ[7]។

18. មេធាវីការពារក្តីសូមលើកឡើងថា មាត្រា ១៦ មិនបានបន្ធូរបន្ថយសារៈសំខាន់នៃមាត្រា ១៥ នោះទេ ហើយលុះត្រាតែ ក.ស.ព មានចេតនាទាញហេតុផលថា សេចក្តីសារភាពមិនបានមកពីការធ្វើទារុណកម្មនោះទេ "តែបានមកពី" អំពើឃោរឃៅ អមនុស្សធម៌ ឬ ការបន្ថោកបន្ទាប ឬ ទណ្ឌកម្មដែលមេធាវីការពារមិនអាចមើលឃើញពីភាពពាក់ព័ន្ធនៃការធ្វើអត្ថាធិប្បាយបែបនេះទេ។

19. ទីបី ក.ស.ព បកស្រាយមិនត្រឹមត្រូវលើកថាខណ្ឌ ១៦ នៃគោលការណ៍ណែនាំសំរាប់ព្រះរាជអាជ្ញាដែលចែងថា គោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិទទួលស្គាល់ "ថាព្រះរាជអាជ្ញាអាចប្រើភស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម *'ប្រឆាំងនឹងជនដែលប្រើប្រាស់វិធីសាស្ត្រយកភស្តុតាងបែបនេះ"* ដោយគ្មានដែនកំណត់"។ ការបន្ថែម "គ្មានដែនកំណត់" ត្រូវបានបន្ថែមដោយ ក.ស.ព[8]។

## ៣.២ ការឆ្លើយតបរបស់ ក.ស.ព ខកខានមិនបានឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ("CAT")

---

[7] កថាខណ្ឌ ១៦ នៃគោលការណ៍ណែនាំសំរាប់ព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិ ១៩៩០ នៅត្រង់ខថាខណ្ឌ ១៣ នៃចម្លើយតបរបស់ ក.ស.ព មិនបានញែកឲ្យដាច់ពីគ្នាពីអំពើទារុណកម្ម អំពើអមនុស្សធម៌ ការបន្ទាបបន្ថោក និង ការដាក់ទណ្ឌកម្មនោះទេ។

[8] អត្ថបទពេញនៃកថាខណ្ឌ ១៦ នៃគោលការណ៍ណែនាំព្រះរាជអាជ្ញារបស់អង្គការសហប្រជាជាតិចែងថាៈ

> នៅពេលព្រះរាជអាជ្ញាទទួលបានភស្តុតាងប្រឆាំងនឹងជនសង្ស័យ ដែលពួកគេដឹង ឬ ជឿជាក់ដោយសមហេតុផលថាភស្តុតាងទាំងនេះទទួលបានតាមវិធីសាស្ត្រខុសច្បាប់ ដែលបង្កើតបានជាការរំលោភយ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមនុស្សរបស់ជនសង្ស័យ ជាពិសេសពាក់ពន្ធជាមួយការធ្វើទារុណកម្ម ឬអំពើឃោរឃៅ ការប្រព្រឹត្តអមនុស្សធម៌ ឬ ការបន្តកបន្ទាប ឬ ទណ្ឌកម្ម ឬ ការរំលោភសិទ្ធិមនុស្សដទៃទៀត នោះពួកគេត្រូវបដិសេធការប្រើប្រាស់ភស្តុតាងបែបនេះប្រឆាំងនឹងជនណាម្នាក់ តែភស្តុតាងបែបនេះអាចត្រូវប្រើប្រាស់ប្រឆាំងនឹងអ្នកប្រើប្រាស់វិធីសាស្ត្រយកភស្តុតាងបែបនេះ ឬ រាយការទៅតុលាការ ហើយត្រូវចាត់វិធានការដើម្បីធានាថា អ្នកទទួលខុសត្រូវលើការប្រើប្រាស់វិធីសាស្ត្រយកភស្តុតាងបែបនេះ ត្រូវបានមកកាត់ទោស។

20. នៅចុងទាំងចម្លើយតប ក.ស.ព បានយោងជាច្រើនលើកច្រើនសារ ទៅលើកម្មវត្ថុ និងគោលបំណង នៃមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ដែលត្រូវបានលើកឡើងយ៉ាងទូលំទូលាយ នៅក្នុងសំណើសុំរបស់មេធាវីការពារ។ ជាបឋម ក.ស.ព បានចង្អុលបង្ហាញថាខ្លួនយល់ព្រម ជាមួយការបកស្រាយ ដូចដែលបានលើកឡើងនៅក្នុងសំណើសុំរបស់មេធាវីការពារ[9] ប៉ុន្តែ នៅក្នុង ចម្លើយតប ក.ស.ព គ្រាន់តែផ្តោតទៅលើផ្នែកមួយនៃការបកស្រាយតែប៉ុណ្ណោះ។ ផ្នែកទីពីរ នៃភាពសមហេតុផលរបស់ខ្លួន ដែលត្រូវបានដោបញ្ជាក់យ៉ាងខ្លាំង ជាពិសេសការទប់ស្កាត់ ការធ្វើទារុណកម្មនាពេលអនាគត និង ផ្នែកទីមួយនៃសនិទានភាព គឺភាពមិនអាចជឿទុកចិត្តបាន នៃភស្តុតាង ត្រូវបានបំភ្លេចចោលទាំងស្រុង។

21. ឧទាហរណ៍ កថាខណ្ឌ ២០ នៃចម្លើតប ក.ស.ព ធ្វើសេចក្តីសន្និដ្ឋានយ៉ាងទូលំទូលាយថា:

> ការមិនរាប់បញ្ចូលនូវភស្តុតាងដែលត្រូវបានជំទាស់ នឹងធ្វើឲ្យកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញា ប្រឆាំងនឹងការធ្វើទារុណកម្ម ទទួលបរាជ័យក្នុងការទប់ស្កាត់ការធ្វើទារុណកម្ម។ មាត្រា ១៥ មានអត្ថិភាពសំរាប់បំរើឲ្យអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម និង គោលបំណងរបស់វាក្នុង ការទប់ស្កាត់ការធ្វើទារុណកម្ម អាស្រ័យហេតុនេះ មាត្រា ១៥ មិនអាចប្រើប្រាស់ដើម្បីលុបបំបាត់ ន័យរបស់អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មបានឡើយ។

ហេតុដូច្នេះ ក.ស.ព បានមើលរំលងការពិតដែលថា មាត្រា ១៥ គឺមានន័យច្បាស់លាស់នៅក្នុងការ បកស្រាយ: ភស្តុតាងដែលផិតដាមដោយការធ្វើទារុណកម្ម មិនអាចប្រើប្រាស់នៅក្នុងតុលាការ បានឡើយ លើកលែងតែភស្តុតាងហ្នឹងប្រើប្រាស់ប្រឆាំងនឹងអ្នកធ្វើទារុណកម្មប៉ុណ្ណោះ ដើម្បី បង្ហាញថាការធ្វើទារុណកម្ម ពិតជាត្រូវបានប្រព្រឹត្តមែន។

22. ក.ស.ព បញ្ចៀសទឡ្ហីករណ៍ដែលអាចឲ្យជឿទុកចិត្តបាន នៅពេលដែលខ្លួនយោងទៅលើ ICTY និង ICTR ដែលបានអនុញ្ញាតឲ្យទទួលយកភស្តុតាងដែលបានមកដោយខុសច្បាប់ តាមរយៈការ រំលោភបំពានលើភាពសំងាត់រវាងមេធាវី និង កូនក្តី, ការឆែកឆេរដោយគ្មានដីកា និង ការស្ទាក់ចាប់ សម្លេងដោយខុសច្បាប់[10]។ វិធីសាស្ត្រអនុវត្តចំពោះភាពអាចទទួលយកបាននៃភស្តុតាងដែលបាន មកដោយខុសច្បាប់ ផ្ទុះបញ្ចាំងពីតុលាការនៅក្នុងប្រព័ន្ធច្បាប់ទីមមីនឡជាច្រើនដែលភស្តុតាងទទួល

[9] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៣។

[10] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៥ ។

បានក្រោមកាលៈទេសៈបែបនេះ មិនបង្កើតនូវមន្ទិលសង្ស័យពីភាពអាចទទួលយកបាន និង ភាពគួរឱ្យជឿទុកចិត្តបានរបស់វា។ ចំនុចនេះផ្ទុយនឹងចរិតលក្ខណៈដែលមិនអាចគួរឱ្យជឿទុកចិត្តបាន ចំពោះភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ។

23. ដូចបានលើកឡើងនៅក្នុងសំណើសុំ មេធាវីការពារច្រានចោលការយល់ឃើញរបស់ ក.ស.ព ថាមាន "ការប៉ះពាល់ដល់ជនត្រូវចោទយ៉ាងតិចបំផុត"។ ក្រៅពីការណ៍ដែលថាមានព្យសនកម្មដល់ជនត្រូវចោទ គឺមិនចាំបាច់តាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មឡើយ ប្រសិនព័ត៌មានដែលភ្ជាប់មកជាមួយមានភាពមិនអាចគួរឱ្យទុកចិត្តបាន ត្រូវបានប្រើប្រាស់ដើម្បីប៉ុនប៉ងបង្ហាញពីការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ នោះដំណើរការបែបនេះនឹងបង្កើតបានជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដូចដែលបានធានាដោយវិធាន ២១ នៃវិធានផ្ទៃក្នុង និងច្បាប់អន្តរជាតិដែលបានចង្អុលបង្ហាញកន្លងមក ជាច្រើនទៀត។

24. ក.ស.ព បានបង្ហាញនូវទិដ្ឋភាពមួយនៃសនិទានរបស់មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម មិនអាចអនុវត្តបានទេ នៅក្នុងករណីនេះ ជាពិសេស ភាពអាចឱ្យជឿទុកចិត្តបានពីកំណើតនៃភស្តុតាងដែលផិតដាមដោយការធ្វើទារុណកម្ម ។ ដោយការនិយាយថា "វាអាចត្រូវបានជំទាស់ថា ការព្រួយបារម្ភអំពីភាពអាចជឿទុកចិត្តបាន [...] អាចចុះថយជាអប្បបរិមា ប្រសិនបើសេចក្តីសារភាពដែលលើកឡើង មិនមែនជាសេចក្តីសារភាពនៃបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែ ជាចម្លើយសារភាពស្រាលៗ ឬជាចម្លើយបញ្ជាក់ពីសាវតារ"[11]។ ក.ស.ព មិនបានផ្តល់ការពន្យល់ ឬអំណះអំណាងណាមួយសម្រាប់សេចក្តីសន្និដ្ឋានដ៏ទូលំទូលាយបែបនេះទេ ហើយ ក៏ពុំបានយោងលើយុត្តិសាស្ត្រដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនផងដែរ។ បន្ថែមពីលើនេះ ក.ស.ព បដិសេធដោយគ្មានមូលដ្ឋានថា ជនរងគ្រោះនៃការធ្វើទារុណកម្ម ត្រូវបានបង្ខំឱ្យផ្តល់ព័ត៌មានមិនត្រឹមត្រូវលើបញ្ហា ដោយគ្រាន់ផ្តល់ព័ត៌មានពីអំពើព្រហ្មទណ្ឌតែប៉ុណ្ណោះ។

25. នៅគ្រប់ករណីទាំងអស់ ដើម្បីបង្ហាញថា ព័ត៌មានជាក់លាក់នៅក្នុងចម្លើយសារភាព មិនបានមកពីការធ្វើទារុណកម្ម គឺជាបន្ទុករបស់ ក.ស.ព បើពិចារណាពីអត្ថន័យច្បាស់លាស់នៃមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ សេចក្តី

[11] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១០ ។

ថ្លែងរបស់ ឌុច នៅក្នុងអង្គសវនាការនាពេលថ្មីៗនេះ អាចត្រូវវាយតំលៃថាបានផ្តល់ភស្តុតាងល្អបំផុត ចំពោះភាពមិនអាចជឿទុកចិត្តបាននៃព័ត៌មាននៅក្នុង "ចម្លើយសារភាព"។

26. ម្យ៉ាងវិញទៀត ខ្លឹមសារនៃមាត្រា ១៥ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មគឺមានន័យច្បាស់លាស់។ អនុលោមតាមចម្លើយតបរបស់ ក.ស.ព បានបញ្ជាក់ថា "អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាបញ្ជាក់ថា: អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មត្រូវតែបកស្រាយឱ្យសមស្របតាមកម្មវត្ថុនិងគោលបំណងរបស់វា"[12]។ ការជ្រើសរើសយកមកបង្ហាញមាត្រា ៣១(១) នៃអនុសញ្ញានេះ ដែលមានចែងពេញលេញដូចខាងក្រោមថា:

> សន្ធិសញ្ញាត្រូវតែបកស្រាយឱ្យបានស្មោះត្រង់ <u>អនុលោមតាមអត្ថន័យធម្មតាដែលបានផ្តល់ឱ្យចំពោះលក្ខខណ្ឌនៃសន្ធិសញ្ញា</u>នៅក្នុងបរិបទរបស់វា ហើយសមស្របតាមកម្មវត្ថុ និង គោលបំណងផងដែរ។

**៣.៣ ពុំមានភាពបត់បែននៅក្នុងការច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម**

27. នៅផ្នែកទី III ក នៃចម្លើយតបរបស់ខ្លួន ក.ស.ព ស្នើឱ្យមានវិធីសាស្ត្រប្រកបដោយភាពបត់បែនមួយដើម្បីទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។ ក.ស.ព បានយោង "គ្រប់តុលាការអន្តរជាតិបណ្តោះអាសន្ន ចាប់ពី ICTY រហូតដល់ SCSL សុទ្ធតែបានបង្កើតយ៉ាងប៉ិនប្រសប់នូវប្រព័ន្ធស្តីពីការទទួលយកភស្តុតាង"[13] ប៉ុន្តែ ខកខានមិនបានទទួលស្គាល់ថា ពុំមានតុលាការអន្តរជាតិបណ្តោះអាសន្នណាមួយ ប្រឈមជាមួយភស្តុតាងដែលទទួលបានមកពីការធ្វើទារុណកម្មនោះទេ។

28. ក.ស.ព មិនយល់ពីចរិតលក្ខណៈតែមួយរបស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម និង ភាពសមហេតុផលសម្រាប់ច្រានចោលការប្រើប្រាស់បែបនេះនៅក្នុងដំណើរការជម្រះក្តី។ វាមិនពាក់ព័ន្ធទេថាតើភស្តុតាងត្រូវវាយតំលៃដោយគណៈវិនិច្ឆ័យ ឬ ចៅក្រមអាជីពនោះ ដោយសារពួក

---

[12] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ២៨ ។

[13] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ១៥ និង កថាខណ្ឌ ១៨ ដែលក.ស.ព បានលើងទៅលើសេចក្តីសម្រេចរបស់ SCSL ទាក់ទងនឹងការទទួលយកភស្តុតាង។

គេមិនអាចញែកឱ្យដាច់ចេញពីគ្នាបានរវាងការពិត និងព័ត៌មានមិនត្រឹមត្រូវនៅក្នុងចម្លើយសារភាព ដែលទទួលបានមកពីការធ្វើទារុណកម្ម ហេតុដូច្នេះរបស់វា មិនអាចផ្ទៀងផ្ទាត់បានទេ។

29. ក.ស.ព ផ្តល់អំណះអំណាងបន្តទៀតថា វិធាន ២៨ នៃវិធានផ្ទៃក្នុង គឺមានសារៈសំខាន់នៅក្នុងការសម្រេចពីភាពបត់បែនលើការប្រើប្រាស់នៅ អ.វ.ត.ក នូវភស្តុតាងដែលផលិតដោយការធ្វើទារុណកម្ម។ ក.ស.ព យោងបទប្បញ្ញត្តិនេះ ដែលចែងយ៉ាងច្បាស់ថា សេចក្តីសម្រេចដើម្បីទទួលយកភស្តុតាង អាចពិចារណាថាតើភស្តុតាងនេះ អាចត្រូវបានដាក់ជំនួសដោយភស្តុតាងពីប្រភពផ្សេងទៀតដែរ ឬយ៉ាងណា។ ម្យ៉ាងវិញទៀត អំណះអំណាងនេះបដិសេធបញ្ហាដែលជាប់មកជាមួយរបស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្មៈ ភាពមិនអាចជឿទុកចិត្តរបស់វា។ ចំពោះសក្ខីកម្មដែលធ្វើឡើងដោយសាក្សីប្រឆាំងលើខ្លួនឯង គឺពុំមានបញ្ហាលើភាពអាចជឿទុកចិត្តបាននោះទេ។ ប៉ុន្តែ អង្គភាពតុលាការអាចវាយតំលៃលើភាពអាចជឿទុកចិត្តបានរបស់សាក្សី តាមរយៈមើលឃើញរបស់គាត់ និង ការសួរសំនួរដល់គាត់ផ្ទាល់។ ការសាកល្បងបែបនេះ គឺមិនអាចអនុវត្តបានទេចំពោះភស្តុតាងដែលផលិតដោយការធ្វើទារុណកម្ម ដែលត្រូវជំទាស់ដោយមេធាវីការពារនោះ។

30. ការសំអាងទៅលើភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ដោយសារតែពុំមានប្រភពផ្សេងទៀតសំរាប់ព័ត៌មានបែបនេះ និងបង្កឱ្យមានៈ

(i) ប្រើប្រាស់ភស្តុតាងដែលមិនអាចជឿទុកចិត្តបាន ក្លាយទៅជាផ្នែកមួយនៃដំណើរការវិនិច្ឆ័យក្តី និង

(ii) ភស្តុតាងបែបនេះមិនអាចជំទាស់ និង តវ៉ាដោយជនជាប់ចោទ និង ចៅក្រមបានឡើយ (ឬដោយអ្នកជំនាញ, សូមមើលកថាខណ្ឌ ៣៧ ខាងក្រោម)។

31. ក្នុងការអះអាងថា “ការដាក់ជំនួសឯកសារសួរចម្លើយទាំងនេះមិនអាចធ្វើទៅបានឡើយ” ក.ស.ព សំអាងទៅលើអត្ថបទសិក្សាស្រាវជ្រាវរបស់ Michael Scharf[14]។ ដោយសារតែភាពសម្ងាត់នៃសំណុំរឿង មេធាវីការពារកត់សម្គាល់ថា លោក Michael Scharf មិនមានសិទ្ធិពិនិត្យមើលព័ត៌មានដែលមាននៅក្នុងសំណុំរឿង នោះទេ។ ក.ស.ព មិនបានផ្តល់ការវិភាគដើម្បីជាការគាំទ្រដល់ការអះអាងរបស់ខ្លួននោះទេ។ លោក Michael Scharf បានយោងទៅលើការពិភាក្សា

[14] សូមមើល ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ១៧, អក្សរក្នុងលេខយោងពីខាងក្រោមត្រង់លេខ ២២ ។

រវាង Craig Etcheson និង Stephen Heder ដែលបានសន្និដ្ឋានបន្ថែមទៀតនៅក្នុងអត្ថបទរបស់គាត់ថា "សាលាក្ដីមិនចាប់អារម្មណ៍លើចម្លើយសារភាពដ៏មានសារៈសំខាន់ដែលជនជាប់ឃុំបានធ្វើនៅក្នុងអំឡុងពេលនៃការធ្វើទារុណកម្មលើរូបរាងកាយនោះទេ"[15]។

32. លើសពីនោះទៅទៀត ក.ស.ព យោងទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ SCSL នៅក្នុងរឿងក្ដីរវាង *រដ្ឋអាជ្ញា តទល់ជាមួយ Moinina Fofana* [16]។ ចម្លើយតបរបស់ ក.ស.ព អះអាងថា SCSL មាន "វិធានស្ដីពីភស្តុតាង ប្រហាក់ប្រហែលគ្នាទៅនឹងវិធានរបស់ អ.វ.ត.ក ដែរ" ដែលការលើកឡើងបែបនេះគឺមិនត្រឹមត្រូវនោះទេ។ SCSL ត្រូវបានគ្រប់ដណ្ដប់ដោយច្បាប់ខឹមមីនឡូ ដែលបានយោងទៅលើប្រព័ន្ធច្បាប់អង់គ្លេស[17] ចំណែកឯ អ.វ.ត.ក ត្រូវបានគ្រប់គ្រងដោយច្បាប់ស៊ីវិល ដែលបានយោងទៅលើប្រព័ន្ធច្បាប់កម្ពុជា និងប្រព័ន្ធច្បាប់បារាំង។ លើសពីនេះទៅទៀត សេចក្ដីសម្រេចទៅលើរឿងក្ដី Fofana ដែល ក.ស.ព បានសំអាងនោះ គឺពាក់ព័ន្ធទៅនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សី ដែលមិនបានចុះហត្ថលេខានៅក្នុងតុលាការដែលអង្គជំនុំជម្រះសាលាដំបូង អាចផ្ទៀងផ្ទាត់លើកំណត់ហេតុផ្ដល់ចម្លើយទាំងនោះក្នុងពេលស្ដាប់ចម្លើយសាក្សី។ ជាថ្មីម្ដងទៀត ក.ស.ព មិនបានរក្សាជំហរដែលចំពោះភស្តុតាងដែលប្រឡាក់ប្រឡូកនឹងការធ្វើទារុណកម្ម ដែលត្រូវដាក់ដោយឡែកពីប្រភេទភស្តុតាងដែលខ្លួនបានសំអាងនោះទេ។

33. នៅក្នុងកថាខណ្ឌទី ១៩ នៃចម្លើយតបរបស់ខ្លួន ក.ស.ព បកស្រាយខុសនូវទឡ្ហីករណ៍របស់ Tobias Thienel ដែលទឡ្ហីករណ៍នោះលើកឡើងថា គោលការណ៍នៃការជំនុំជម្រះក្ដីដោយយុត្តិធម៌ជាប់ទាក់ទងនឹងសិទ្ធិប្រឆាំងនឹងការធ្វើសក្ខីកម្មដាក់បន្ទុកលើខ្លួនឯង[18]។ ក.ស.ព មិនបានយកចិត្តទុកដាក់ចង្អុលបង្ហាញឲ្យឃើញថា ការកត់សម្គាល់នេះត្រូវបានធ្វើឡើងដោយ Thienel នៅក្រោម

---

[15] Scharf ប្រវត្តិប្រឡាក់ប្រឡូក (Tainted Provenance) ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងធ្វើទារុណកម្មអាចទទួល យកបាន? in: 65 Wash & Lee. Rev. 129 (Winter 2008), at 140 យោងទៅលើ "ការបិភាក្សារវាង Craig Etcheson និង Stephen Heder ទីប្រឹក្សា ក.ស.ព នៃ អ.វ.ត.ក នៅទីក្រុងភ្នំពេញ កម្ពុជា ថ្ងៃទី ២៤ ខែ តុលា ២០០៦ ។

[17] សូមមើល ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ១៨, យោងរឿងក្ដីរវាង *រដ្ឋអាជ្ញា តទល់នឹង Fofana និងអ្នកផ្សេងទៀត,* Fofana - បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធការសុំនៅក្រៅឃុំ ដោយមានការដាក់តម្កល់ ប្រាក់ធានា, សំណុំរឿងលេខ SCLS-04-14-AR65 ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០០៥ ត្រង់កថាខណ្ឌទី ២៤។

[18] សូមមើល ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ១៩ ។

ចំណងជើង "ក) ការប្រើប្រាស់ភស្តុតាង ដែលប្រឡាក់ប្រឡូកជាមួយការធ្វើទារុណកម្ម *មកលើបុគ្គលទទួលរងទារុណកម្ម* នៅក្នុងតុលាការ"[19]។ បញ្ហានៅទីនេះ គឺមិនមែនការប្រើប្រាស់ភស្តុតាងដែលប្រឡាក់ប្រឡូកប្រឆាំងនឹងបុគ្គលដែលបានរងការធ្វើទារុណកម្មនោះទេ។ ដូច្នោះ ការជំនុំជម្រះក្តីដោយយុត្តិធម៌ ត្រូវបាន ក.ស.ព យល់ខុស ដែលការជំនុំជម្រះនោះទាក់ទងទៅនឹងការរំលោភដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ទាំងស្រុង ចំពោះការរំលោភបំពានលើសិទ្ធិប្រឆាំងនឹងការធ្វើសក្ខីកម្មដាក់បន្ទុកលើខ្លួនឯង។ ការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានរំលោភបំពាន ដោយការប្រើប្រាស់ភស្តុតាង ដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្មនៅក្នុងដំណើរការនីតិវិធីប្រឆាំងមកលើរូបអ្នកស្រី ដែលមានទំហំស្មើនឹងការរំលោភវិធាន ២១ នៃវិធានផ្ទៃក្នុង។

### ៣.៤ ប្រភេទនៃភស្តុតាង

**(i) គោលនយោបាយបក្សកុំមុយនីស្តកម្ពុជា**

34. នៅក្នុងផ្នែក គ នៃចម្លើយតបរបស់ខ្លួន ក.ស.ព ព្យាយាមវិភាគទៅលើខ្លឹមសារនៃចម្លើយសារភាពដែលមានការតវ៉ា។ មេធាវីការពារសូមលើកឡើងថា ការប៉ុនប៉ងវិភាគគឺរំលោភទៅលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ ដោយសារតែការសំអាងនេះតែមួយមុខ ហេតុនេះ ទឡ្ហីករណ៍របស់ ក.ស.ព គួរតែត្រូវបានច្រានចោល។

35. ក.ស.ព លើកឡើងថា ការប្រើប្រាស់ព័ត៌មានដែលប្រឡាក់ប្រឡូកនឹងការធ្វើទារុណកម្ម គួរតែត្រូវបានអនុញ្ញាតឲ្យពន្យល់ពីឋានានុក្រម ការប្រាស្រ័យទាក់ទង និងគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជា[20]។ ព័ត៌មាននេះអាចត្រូវបានយកមកចោទប្រកាន់ចំពោះជនជាប់ចោទ តាមរយៈទស្សនាទាននៃការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ និងសហកម្មឧក្រិដ្ឋកម្មរួម ដូចដែលបានជំទាស់តវ៉ា។ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម គឺច្បាស់លាស់នៅក្នុងបញ្ហានេះ។ ភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មនឹងមិនត្រូវបានយកមកប្រើប្រាស់នោះទេ "វៀរលែងតែប្រឆាំងនឹងបុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីអំពើទារុណកម្ម ថាជាភស្តុតាង

[19] T. Thienel, "ការទទួលយកភស្តុតាង ដែលទទួលបានមកដោយការធ្វើទារុណកម្ម នៅក្រោមច្បាប់អន្តរជាតិ" នៅក្នុងព្រឹត្តិប័ត្រច្បាប់អន្តរជាតិរបស់អឺរ៉ុប 17 (2006) 349, at 356 (មានបញ្ជាក់បន្ថែម)។

[20] សូមមើល ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ២៤ ។

បញ្ជាក់ថា កំណត់ហេតុសួរយកចម្លើយ ត្រូវបានធ្វើឡើងមែន"[21]។ អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មហាមឃាត់ចំពោះការប្រើប្រាស់ទូលំទូលាយនៃចម្លើយសារភាព។ ទោះបីជាត្រូវបានប្រើប្រាស់នៅក្នុងទ្រឹស្តីនៃការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើក្តី ឬក្នុងសហកម្មឧក្រិដ្ឋកម្មរួមក្តី គឺមិនពាក់ព័ន្ធនោះទេ។ កំណត់ហេតុសួរចម្លើយនោះ អាចត្រូវបានយកមកប្រើប្រាស់ប្រឆាំងតែទៅនឹងជនជាប់ចោទនៃអំពើទារុណកម្ម ដើម្បីបញ្ជាក់ថា កំណត់ហេតុសួរចម្លើយនោះត្រូវបានធ្វើឡើងមែន។

**(ii) សេចក្តីថ្លែងការណ៍របស់អ្នកជំនាញ**

36. ដូចគ្នាផងដែរ មាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ក៏ច្រានចោលយោបល់របស់អ្នកជំនាញ ដែលបានសំអាងទៅលើភស្តុតាងប្រឡាក់ប្រឡូកនឹងអំពើទារុណកម្ម។ ត្រឡប់មកវិញ ព័ត៌មានដែលបានសំអាងដោយអ្នកជំនាញរបស់ ក.ស.ព ដែលអះអាងទៅលើភស្តុតាងប្រឡាក់ប្រឡូកនឹងអំពើទារុណកម្ម គឺមិនអាចជឿជាក់បានឡើយ ហេតុដូច្នេះ មិនគួរត្រូវបានយកប្រើប្រាស់ប្រឆាំងនឹងជនជាប់ចោទនៅក្នុងដំណើរការនីតិវិធីប្រឆាំងមកលើរូបអ្នកស្រីនោះទេ។ ខណៈដែលយោបល់របស់អ្នកជំនាញផ្ទាល់អាចត្រូវបានយកមកសាកល្បង តាមរយៈការសាកសួរដេញដោលនោះប្រភពនៃយោបល់គាត់ "យោបល់អ្នកជំនាញ" មិនអាចយកមកសាកល្បងបានទេ និងត្រូវចាត់ទុកថាមិនអាចជឿទុកចិត្តបានឡើយ។ ក.ស.ព មិនបានពន្យល់ថាហេតុអ្វីបានជា "អ្នកជំនាញ" អាចវែកញែកឱ្យដាច់ពីគ្នារវាងព័ត៌មានគួរឱ្យទុកចិត្តបាន និងព័ត៌មានមិនឱ្យទុកចិត្តបាននៅក្នុងកំណត់ហេតុសួរចម្លើយបែបនោះ ខណៈដែលចៅក្រមវិជ្ជាជីវៈមិនអាចធ្វើការវែកញែកបែបនោះបានទៅវិញ តាមរយៈមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម។ ក្នុងន័យនេះ យុត្តិសាស្ត្ររបស់ ICTR និង ICTY ដែល ក.ស.ព ធ្វើការសំអាងនោះ គឺមិនទាក់ទងទៅនឹងការប្រើប្រាស់ព័ត៌មាន ដែលបានមកពីអំពើទារុណកម្មនោះទេ[22]។ ពុំមានតុលាការណាមួយដែលមាន

[21] មានបញ្ជាក់បន្ថែម ។

[22] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ៣៥។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនៃ ICTY ដែលបានលើកឡើងនៅក្នុងរឿងក្តីរវាង រដ្ឋអាជ្ញា តទល់នឹង Perisic, សេចក្តីសម្រេចទៅលើរបាយការណ៍របស់អ្នកជំនាញដោយ Richard Phillips, សំណុំរឿងលេខ IT-04-81-T, ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៩ ត្រង់កថាខណ្ឌទី ៦ លើកឡើងយ៉ាងច្បាស់ថា លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌជាច្រើន សម្រាប់ការទទួលយករបាយការណ៍របស់អ្នកជំនាញនោះគឺ "យោបល់របស់ ឬរបាយការណ៍របស់អ្នកជំនាញ ត្រូវឆ្លើយតបទៅនឹងបទដ្ឋានអប្បបរមានៃភាពគួរឱ្យជឿទុកចិត្តបាន"។ លើសពីនេះទៅទៀត កថាខណ្ឌទី ១០ នៃសេចក្តីសម្រេចនេះលើកឡើងថា: "យោងតាមវិធាន ៨៩ស្ទួននៃវិធានស្តីពីភស្តុតាងគឺ ភស្តុតាងដែលត្រូវ

00327278



យុត្តាធិការចំពោះអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម នឹងអនុញ្ញាតឱ្យទទួលយកលទ្ធផលនៃការធ្វើទារុណកម្មនៅក្នុងបន្ទប់សវនាការនោះទេ លើកលែងតែ ដូចមានចែងនៅក្នុងមាត្រា ១៥ "ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីការធ្វើទារុណកម្ម ថាជាភស្តុតាងដែលបញ្ជាក់ថា កំណត់ហេតុសួរចម្លើយនោះត្រូវបានធ្វើឡើងមែន"។

37. ក.ស.ព លើកឡើងថា "អង្គហេតុឬទិន្នន័យណាក៏ដោយ ក៏អាចយកទៅប្រើប្រាស់ធ្វើជាមូលដ្ឋាននៃសក្ខីកម្មរបស់អ្នកជំនាញបានដែរ[23]" គឺស្មើនឹងការគេចវៀសវេះពីមាត្រា ១៥ ហើយអាស្រ័យហេតុនេះ គួរតែត្រូវបានច្រានចោល។ ពុំមានការវែកឱ្យដាច់ពីគ្នាត្រូវបានគេធ្វើឡើងរវាងអ្នកជំនាញ និងចៅក្រម ឬគណៈវិនិច្ឆ័យ ដែលសម្រេចសេចក្ដីទៅលើអង្គហេតុនៃរឿងក្ដីមួយនោះទេ ហើយក៏ពុំមានហេតុផល ណាមួយដែលត្រូវធ្វើការវែកញែកដូច្នោះដែរ។

38. ឯកសាររបស់លោក Craig Etcheson ដែលបានដាក់ជាឧបសម្ព័ន្ធភ្ជាប់ទៅនឹងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ មានការយោងទៅលើចម្លើយសារភាពជាងចិតសិប ដែលបានមកពីមន្ទីរ ស-២១[24]។ តាមរយៈឯកសារនេះ ចម្លើយសារភាពដែលបានពីមន្ទីរស-២១ ទាំងអស់កំពុងត្រូវបានប្រើប្រាស់ជាភស្តុតាងនៃឋានានុក្រមរបស់កម្ពុជាប្រជាធិបតេយ្យ និងជាគោលនយោបាយរបស់ខ្មែរក្រហម។ ប៉ុន្តែ លោក Etcheson មិនដែលសំអាងទៅលើចម្លើយសារភាពឱ្យលើសពីមួយ ឬពីរនោះទេ នៅពេលដែលគាត់ប្រើប្រាស់ឯកសារទាំងនេះជាប្រភព សម្រាប់ឱ្យគាត់ទាញសេចក្ដីសន្និដ្ឋានឱ្យបានទូលំទូលាយនោះ[25]។ ហេតុដូច្នេះ ការលើកឡើងថា កំណត់ហេតុសួរចម្លើយដែលទាក់ទងទៅ

---

ដាក់បញ្ចូលជាភស្តុតាង ត្រូវតែបំពេញលក្ខខណ្ឌទូទៅនៃភាពអាចទទួលយកបានផងដែរ។ ហេតុដូច្នេះ ភស្តុតាងដែលបានស្នើឡើងត្រូវតែជាប់ពាក់ព័ន្ធ និងត្រូវតែមានតម្លៃសាកល្បង (probative value) ហើយតម្លៃសាកល្បងនេះមិនត្រូវបានចាត់ទុកថាសំខាន់ខ្លាំងជាង តាមរយៈតម្រូវការឱ្យមានការជំនុំជម្រះក្ដីមួយប្រកបដោយយុត្តិធម៌នោះទេ"។

[23] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ៣៤ ។

[24] [redacted]

[25] [redacted]

និងឋានានុក្រម ការប្រាស្រ័យទាក់ទង និងការអនុវត្តគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ "ត្រូវបានធ្វើឡើងដោយជនរងគ្រោះម្នាក់ ហើយម្នាក់ទៀតនោះ[26]" គឺមិនត្រឹមត្រូវនោះទេ យ៉ាងហោចណាស់ក៏នៅក្នុងឯកសារដែលបានព្រាងឡើងដោយ Craig Etcheson នោះដែរ ហើយគួរតែត្រូវបានច្រានចោល។

39. ក្នុងករណីណាក៏ដោយ ការប្រើប្រាស់អ្នកជំនាញគួរតែត្រូវបានរក្សាទុក ដើម្បីដោះស្រាយជាមួយអង្គហេតុទាំងឡាយណា ដែលហួសពីការយល់ដឹងរបស់ចៅក្រមចៅក្រម[27]។

40. ក.ស.ព ជំទាស់តវ៉ាថា ចម្លើយសារភាពដំបូងរបស់ជនរងគ្រោះនៅមន្ទីរ ស-២១ គឺមិនមែនបានមកដោយការធ្វើទារុណកម្មនោះទេ ដែលក្នុងនោះ ក.ស.ព លើកឡើងថា "ព័ត៌មានអំពីប្រវត្តិរូបដែលបានរកឃើញនៅក្នុងការសួរចម្លើយដំបូងអាចឲ្យគេអះអាងបានថា មិនមែនបានមកពីការធ្វើទារុណកម្ម នោះទេ ហើយអាចឲ្យជឿទុកចិត្តបានថា ជាផលវិបាកមួយ"[28]។ ក.ស.ព លើកឡើងពីបញ្ហានៃបន្ទុកលើភស្តុតាង និងជំទាស់តវ៉ាថា "ក្នុងករណីនេះ គឺមានតែជនដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មទេ ដែលអាចមានសមត្ថភាពជាងគេបំផុតក្នុងការបង្ហាញភស្តុតាងថាតើមានការធ្វើទារុណកម្ម ឬមិនមាននោះ ព្រោះជនរងគ្រោះដោយការធ្វើទារុណកម្មត្រូវបានគេសម្លាប់ចោលស្ទើរតែអស់ទៅហើយ"[29]។ មេធាវីការពារសូមលើកឡើងសារជាថ្មីពីមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាដែលចែងថា "ចម្លើយសារភាពដែលបានមកដោយការបង្ខិតបង្ខំលើផ្លូវកាយ ឬផ្លូវចិត្ត មិនត្រូវទទួលយកជាភស្តុតាងនៃពិរុទ្ធភាពឡើយ។ រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍

---

[26] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ២៤។ [redacted]

[27] សូមមើល May & Wierda, ភស្តុតាងព្រហ្មទណ្ឌអន្តរជាតិ (២00២) ទំព័រទី ១៩៩ ។

[28] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ២៥។

[29] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ២៧។

ដល់ជនជាប់ចោទ"។ នេះជាករណីមួយសម្រាប់ ក.ស.ព ព្រោះថា វាជាទម្លាប់ទៅហើយដែលចម្លើយសារភាពត្រូវបានទទួលមកពីបុគ្គលទាំងឡាយ ដោយសារតែលទ្ធផលនៃវិធីសាស្ត្រធ្វើទារុណកម្ម។ ចំនុចនេះត្រូវបានគាំទ្រដោយភស្តុតាងរបស់ ឌុច និងអ្នករៀបរៀងប្រវត្តិសាស្ត្រជាច្រើន។ បន្ទុកនៃភស្តុតាងដើម្បីបង្ហាញថាចម្លើយសារភាព គឺមិនមែនបានមកដោយសារការធ្វើទារុណកម្មនោះ គឺអាស្រ័យលើ ក.ស.ព។

41. ក.ស.ព ស្នើឡើងថា ការចោទប្រកាន់ពីបទធ្វើទារុណកម្មប្រឆាំងមកលើជនត្រូវចោទ មិនអាចត្រូវបានស៊ើបអង្កេត និងជំនុំជម្រះ ដោយមិនមានការសំអាងទៅលើភស្តុតាងដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្មនោះទេ ហើយបើដូច្នេះ វានាំឲ្យរំលោភដល់កាតព្វកិច្ចរបស់កម្ពុជាក្នុងការស៊ើបអង្កេត និងផ្តន្ទាទោសចំពោះអំពើទារុណកម្ម ដូចដែលមានចែងក្នុងមាត្រា ១២ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម[30]។ មេធាវីការពារសូមក្រើនរំលឹកដល់ ក.ស.ព ថា ភស្តុតាងដែលប្រឡាក់ប្រឡូកដោយការធ្វើទារុណកម្មមិនអាចត្រូវបានប្រើប្រាស់ "ប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្មថាជា កំណត់ហេតុសួរចម្លើយដែលត្រូវបានធ្វើឡើងនោះឡើយ"។ ការប្រើប្រាស់ភស្តុតាងនេះប្រឆាំងនិងបទចោទផ្សេងទៀតនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺត្រូវបានហាមឃាត់យ៉ាងច្បាស់ក្រឡែត ដោយអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ។

42. ក.ស.ព បញ្ជាក់ថា ចំណារទាំងឡាយនៅលើចម្លើយសារភាពអាចទទួលយកបាន[31]។ ក.ស.ព ត្រូវតែអះអាងពីយថាភាពនៃចំណារទាំងនោះ គឺជាបញ្ហាមួយផ្សេងទៅវិញ។ ជាថ្មីម្តងទៀត ចម្លើយសារភាពមិនអាចត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្ហាញពីភាពឲ្យទុកចិត្តបាន និងភាពត្រឹមត្រូវតាមច្បាប់នៃចំណារទាំងនោះ ដែលអាចត្រូវហាមឃាត់ដោយមាត្រា ១៥។

## IV សេចក្តីសន្និដ្ឋាន

43. ដោយសារតែដំណើរការនីតិវិធីទាំងនេះ ត្រូវបានធ្វើឡើងប្រឆាំងនិងឧក្រិដ្ឋជនសង្គ្រាម នោះការជំទាស់តវ៉ាទាំងអស់នៅក្នុងចម្លើយតបរបស់ ក.ស.ព ហាក់ដូចជាត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់

---

[30] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ៣៧ ។

[31] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ៣៨-៣៩ ។

ភស្តុតាង ដែលប្រឡាក់ប្រឡូកនឹងការធ្វើទារុណកម្ម។ ដូច Scharf លើកឡើងថា "ភស្តុតាងនៅមន្ទីរឃុំឃាំង ទួលស្លែងមានសារៈសំខាន់ចំពោះការផ្តន្ទាទោសប្រកបដោយជោគជ័យ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[32]។ មេធាវីការពារសូមលើកឡើងថា ជនត្រូវចោទមានសិទ្ធិត្រូវបានសន្មត់ថាគ្មានទោស ដរាបណាមិនទាន់រកឃើញថាមានពិរុទ្ធភាពនោះទេ។ វាមិនស្របទៅនឹងបទដ្ឋានច្បាប់អន្តរជាតិ ដែលកម្ពុជា និង អ.វ.ត.ក ត្រូវតែទទួលយកភស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម ដោយមិនគិតពីផលវិបាកនៃការមិនទទួលយកភស្តុតាងនោះទេ។

44. នៅក្នុងចម្លើយតបរបស់ខ្លួន ក.ស.ព រំលោភទៅលើការសន្មតថាគ្មានទោសទុកជាមុន ដោយលើកឡើងថា:

> ការរារាំងចំពោះភស្តុតាងដែលអាចប្រកែកតវ៉ាបាន មុខជានឹងលើកទឹកចិត្តដល់អ្នកទាំងឡាយដែលបានចូលរួមដែលនាំឲ្យមានការធ្វើទារុណកម្ម ដោយអនុញ្ញាតឲ្យពួកគេប្រើប្រាស់ច្បាប់អន្តរជាតិនានា ដែលត្រូវបានបង្កើតឡើងទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើទារុណកម្ម ដើម្បីកុំឲ្យរួចខ្លួន។[33]

ក.ស.ព មិនបានកត់សម្គាល់ថា ច្បាប់អន្តរជាតិទាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិរបស់បុគ្គលទាំងឡាយដែលត្រូវបានសន្មតថាគ្មានទោស ដរាបណាមិនរកឃើញថាមានពិរុទ្ធភាពនោះទេ។

45. នៅក្នុងចម្លើយរបស់ខ្លួន ក.ស.ព មិនបានសំអាងទៅលើរឿងក្តីណាមួយឡើយ ដែលតុលាការជាតិ ឬ អន្តរជាតិបានទទួលយកភស្តុតាងដែលបានមកពីការធ្វើទារុណកម្មនោះទេ[34]។ យើងសូមស្នើថា ការពន្លាតអញ្ញត្រកម្មនៃមាត្រាទី ១៥ អាចធ្វើឲ្យបាត់បង់ប្រសិទ្ធភាពអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ហើយនឹងតួនាទីរបស់អនុសញ្ញានេះនៅក្នុងការប្រយុទ្ធប្រឆាំងនឹងការធ្វើទារុណកម្ម

---

[32] M.P. Scharf, "ប្រវត្តិប្រឡាក់ប្រឡូក (Tainted Provenance): ប្រសិនបើអាច តើនៅពេលណាដែលភស្តុតាងធ្វើទារុណកម្មអាចទទួលយកបាន?" in: 65 Wash & Lee L. Rev. 129 (Winter 2008), at 139.

[33] ចម្លើយតបរបស់ ក.ស.ព ត្រង់កថាខណ្ឌទី ២២ ។

[34] ក្រៅតែពីការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ហើយដែលត្រូវបានច្រានចោលដោយប្រទេសបារាំង ហូឡង់ សហរដ្ឋអាមេរិក និង អង់គ្លេស។ រឿងក្តីទាំងនេះរួមមាន: A ប្រឆាំងនឹងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ(លេខ២) ចុះថ្ងៃទី ៨ ធ្នូ ២០០៥ ត្រង់កថាខណ្ឌទី៣៧ ដល់ ៣៨ ។

ក្នុងពេលកាត់សេចក្តីនៅជុំវិញពិភពលោក។ ការអះអាងដែលបានលើកឡើងដោយ ក.ស.ព អាចនាំឲ្យមានយល់ច្រឡំទៅលើបទប្បញ្ញត្តិទាំងនេះ និងត្រូវតែច្រានចោល។

## V សំណូមពរ

46. សំរាប់ហេតុផលដែលបានលើកឡើងខាងលើនេះ មេធាវីការពារក្តីសូមស្នើ ក.ស.ច.ស:

(i) បដិសេធភស្តុតាងទាំងឡាយនេះ ឬឯកសារដទៃទៀត ដែលបានមកពីការធ្វើទារុណកម្ម ក្រៅពីការបង្ហាញឲ្យឃើញថា ចម្លើយសារភាពនោះបានមកដោយការធ្វើទារុណកម្ម និងសំរាប់ប្រឆាំងតែទៅលើអ្នកធ្វើទារុណកម្ម រួមមាន តែមិនកំណត់ត្រឹមតែ:

(ក) [redacted][35]

(ខ) [redacted][36]

(គ) [redacted][37]

(ឃ) ភស្តុតាងជំនាញដែលសំអាងទៅលើចម្លើយសារភាព ដូចជា ឯកសារលេខ [redacted]។

(ii) ហាមឃាត់ការប្រើប្រាស់ចម្លើយសារភាពទាំងនោះ ដោយមធ្យោបាយណាមួយ ក្រៅពីការលើកឡើងខាងនៅក្នុងចំនុច (i) និង (ii) ខាងលើ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៩ ។

---

[35] [redacted]

[36] [redacted]

[37] [redacted]

ឯកសារ: D130/6

០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស

មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ

លោក ផាត់ ពៅស៊ាង

កញ្ញា **Diana ELLIS, QC**